ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 09 / 2015
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៥

**ផ្ញើជូន៖** ឯកឧត្តម ក្រាញ់ តូនី
ប្រធានស្ដីទីការិយាល័យរដ្ឋបាល
លោក Knut Rosandhaug
អនុប្រធានការិយាល័យរដ្ឋបាល

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង
មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង
ប្រធានអង្គភាពគាំពារការការពារក្ដី
ឯកអគ្គរដ្ឋទូត David Scheffer
អ្នកជំនាញពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកជំនួយអង្គការសហប្រជាជាតិសម្រាប់ការជំនុំជម្រះក្ដីខ្មែរក្រហម

---

**កម្មវត្ថុ៖** សំណើសុំការបំភ្លឺអំពីធនធានបន្ថែមសម្រាប់ក្រុមមេធាវីការពារក្ដីក្នុងសំណុំរឿង ០០២/០២

១. នៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ លោក Victor Koppe ជាសហមេធាវីអន្តរជាតិការពារក្ដី នួន ជា បានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា ក្រុមមេធាវីការពារក្ដី នួន ជា មិនអាចចាត់ចែងបន្ទុកការងារក្នុងសំណុំរឿង ០០២/០២ បានទេ ដោយសារមានការដាក់បង្ហាញឯកសារជាច្រើនពីសំណុំរឿង ០០៣ និង ០០៤ (ឯកសារដែលបានដាក់បង្ហាញ) ទន្ទឹមនឹងការ

ធ្វើសវនាការដ៏មមាញឹក (ប្រតិចារឹកសវនាការថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ (សេចក្ដីព្រាង) ទំព័រ ៦ ដល់ ៧ (ភាសាអង់គ្លេស))។ គាត់បានលើកឡើងទៀតថា ករណីនេះកើតឡើងជាពិសេសនៅក្នុងស្ថានភាពមួយដែលថា ក្នុងពេលដំណាលគ្នានោះ ពួកគាត់ជាប់រវល់ត្រៀមរៀបចំសម្រាប់សវនាការលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ថែមទៀត (ប្រតិចារឹកសវនាការថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ (សេចក្ដីព្រាង) ទំព័រ ៧ (ភាសាអង់គ្លេស))។ ហេតុនេះ គាត់បានស្នើសុំឱ្យផ្ដល់ "ធនធានបន្ថែមភ្លាមៗ" ឬ ក៏ផ្អាកសវនាការទៅលើការប្រព្រឹត្តិចំពោះជនជាតិចាម ដើម្បីមានពេលវេលាសម្រាប់អាន និង ពិនិត្យលើឯកសារដែលបានដាក់បង្ហាញ (ប្រតិចារឹកសវនាការថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ (សេចក្ដីព្រាង) ទំព័រ ៧ (ភាសាអង់គ្លេស))។ លោកមេធាវី Koppe ក៏បានថ្លែងថា ទោះបីជាក្រុមរបស់គាត់ "ត្រូវការជាចាំបាច់នូវបុគ្គលិក ឬ ទីប្រឹក្សាច្បាប់បន្ថែមទៀត" ក៏ដោយ ក៏សំណើសុំធនធានបន្ថែមជាច្រើនត្រូវបានបដិសេធដោយការិយាល័យរដ្ឋបាល (ប្រតិចារឹកសវនាការថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ (សេចក្ដីព្រាង) ទំព័រ ១២ (ភាសាអង់គ្លេស))។

២. មេធាវីការពារក្ដី ខៀវ សំផន ក៏បានលើកឡើងថា ពួកគេពុំមានលទ្ធភាពពិនិត្យឱ្យបានត្រឹមត្រូវទៅលើ "ឯកសារដ៏ច្រើនសន្ធឹកសន្ធាប់" ដែលកំពុងត្រូវបានដាក់បង្ហាញនោះទេ (ប្រតិចារឹកសវនាការថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ (សេចក្ដីព្រាង) ទំព័រ ១០ (ភាសាអង់គ្លេស) ឯកសារ E363 ឯកសារ E363/2) និង បានលើកឡើងថា ពួកគេពុំមានបុគ្គលិកគ្រប់គ្រាន់ដើម្បីពិនិត្យទៅលើបញ្ហានានាដែលពាក់ព័ន្ធនឹងការដាក់បង្ហាញនេះដែរ (ឯកសារ E363 កថាខណ្ឌ ៤១)។

៣. អង្គជំនុំជម្រះកត់សម្គាល់ថា ការដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង ០០៤ បន្ថែមបន្ទុកការងារច្រើនថែមទៀតដល់ភាគីទាំងអស់ រួមទាំងក្រុមមេធាវីការពារក្ដីទាំងពីរក្រុម។ បើតាមព័ត៌មាននាពេលថ្មីៗដែលការិយាល័យសហព្រះរាជអាជ្ញាបានផ្ដល់នោះ ការដាក់បង្ហាញឯកសារបែបនេះទំនងជាបន្តធ្វើរហូតដល់ចប់សវនាការដេញដោលលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២។ លទ្ធភាពរបស់ភាគីក្នុងការរ៉ាប់រងបន្ទុកការងារបន្ថែម ក្នុងពេលដែលត្រូវចូលរួមសវនាការដែលកំពុងធ្វើនេះ នឹងពិតជាមានផលប៉ះពាល់ដល់កាលវិភាគសវនាការជាក់ជាមិនខាន។

៤. ទាក់ទិននឹងបញ្ហានេះ និង ដោយពិចារណាទៅលើសារណាដែលក្រុមមេធាវីការពារក្តីនីមួយៗបានដាក់ អង្គជំនុំជម្រះស្នើសុំទៅការិយាល័យរដ្ឋបាលឱ្យផ្តល់នូវព័ត៌មានខាងក្រោម៖

(១) តើមេធាវីការពារក្តី នួន ជា បានដាក់សំណើជាផ្លូវការសុំធនធានបន្ថែមក្នុងពេលណាមួយចាប់ពីខែ មករា ឆ្នាំ ២០១៥ ដែរ ឬ ទេ? ប្រសិនបើបានស្នើសុំ តើសំណើទាំងនេះធ្វើឡើងនៅពេលណា ហើយសំណើទាំងនេះទទួលបានលទ្ធផលយ៉ាងណា? ក្នុងករណីដែលសំណើទាំងនេះត្រូវបានបដិសេធ តើការបដិសេធទាំងនេះត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋានអ្វីខ្លះ?

(២) ដោយសារការដាក់បង្ហាញឯកសារជាបន្តបន្ទាប់ពីសំណុំរឿងផ្សេងដែលនាំឱ្យមានបន្ទុកការងារបន្ថែម តើក្រុមមេធាវីការពារក្តីអាចទទួលបានធនធានបន្ថែម ដែរ ឬ ទេ?

៥. អង្គជំនុំជម្រះស្នើសុំការិយាល័យរដ្ឋបាលឆ្លើយតបមកអង្គជំនុំជម្រះវិញទៅលើបញ្ហាដូចបានលើកឡើងខាងលើត្រឹមថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥។